## តំលៃ

សហគ្រាសដែលចូលរួម និងត្រូវបង់ប្រាក់ឈ្នួលតិចតួច ដើម្បីអោយមានការបណ្តុះបណ្តាលនេះនៅក្នុងរោងចក្ររបស់ពួកគេ។ សហគ្រាសក៏អាចជ្រើសរើសប្រធានបទណាដែលមានសារៈសំខាន់បំផុតចំពោះតម្រូវការជាក់លាក់របស់រោងចក្រពួកគេផងដែរ។ ថ្លៃឈ្នួលសម្រាប់វគ្គមានតំលៃ ១០០ដុល្លារអាមេរិច និងមានការបញ្ចុះតំលៃសម្រាប់អ្នកដែលជាវសេវាកម្មទាំង៦វគ្គជាឈុត (តំលៃសរុបទាំង៦វគ្គ គឺ៥០០ដុល្លារអាមេរិច )។ នៅក្នុងនោះមានរាប់បញ្ចូលវីដេអូមួយឈុតសម្រាប់រោងចក្រ និងឯកសារៀនរៀបចំផ្តល់កម្មករដែលបានចូលរួមផងដែរ។ ថ្លៃឈ្នួលនេះគឺជាវិភាគទានចែករំលែកថ្លៃដើមជាមួយអង្គការពលកម្មអន្តរជាតិតាមរយៈ *រោងចក្រកាន់តែប្រសើរនៅកម្ពុជា* រួមជាមួយនឹងថ្លៃដើមផ្សេងៗទៀតតាមរយៈការឧបត្ថម្ភគាំទ្រពីម្ចាស់ជំនួយរបស់យើង ។

## ភាពជោគជ័យរបស់កម្មវិធី



"វីដេអូភាគនេះ បានបង្កើតឱ្យមានការយល់ដឹងអំពី សិទ្ធិ និងការទទួលខុសត្រូវរបស់កម្មករនិយោជិត។ ពួកគេ អាចឆ្លុះបញ្ចាំងការដឹកនាំមិនល្អរបស់តំណាងកម្មករ ដូចជាតួអង្គកុសលដែលគិតតែបំពេញបំណងប្រាថ្នារបស់ខ្លួនឯងដោយធ្វើឱ្យអ្នកដទៃទទួលរងការខាតបង់។ កម្មករមិនគួរជឿលើតំណាងកម្មករដែលខ្ចិលទេ។ គេអាចជ្រើសរើសដើរតាមនីតិវិធីដោះស្រាយបណ្តឹងសារទុក្ខជំនួសឱ្យការធ្វើតាមអ្នកដឹកនាំអាក្រក់។"

*អ្នកស្រី ថៃ ម៉ារីណា ប្រធានសហជីពនៃរោងចក្រកាត់ដេរកម្ពុជា អាកមើត*



"វីដេអូភាគបានជួយបង្កើតការយល់ដឹងអំពីច្បាប់ សិទ្ធិ និងការទទួលខុសត្រូវរបស់កម្មករពីព្រោះក្រោយពីការចាក់ផ្សាយក្នុងរោងចក្រមក បច្ចុប្បន្នពួកគេប្រើប្រាស់ម៉ាស់ដើម្បីការពារសុខភាព។ គេយល់ថាការលួច គឺជាកំហុសមួយធ្ងន់ធ្ងរណាស់ ហើយអ្នកលួចនោះនឹងត្រូវផ្តន្ទាទោសដោយច្បាប់ ហើយកម្មករនិយោជិតថ្មី មិនតម្រូវឱ្យបង់លុយដើម្បីបានការងារធ្វើទេ ។ ការផលិតនេះពិតជា មានសារៈសំខាន់ណាស់ សម្រាប់ទាំងកម្មករ និងរោងចក្រ"។

*លោក ថេមី ឌួង ប្រធានផ្នែកគ្រប់គ្រងធនធានមនុស្សនៃរោងចក្រហ្គោលបៀម*



"ខ្ញុំគិតថានៅពេលដែលវីដេអូនេះ បានដាក់បញ្ចាំងជូនដល់កម្មករ តំណាងរបស់ពួកគេ និងនិយោជកទាំងអស់វាបានជួយដល់យើងអោយបានយល់ដឹងពី វិធីក្នុងការដោះស្រាយបញ្ហាជាជំហានៗ។ យើងមិនគួរគ្រាន់តែដើរតាមមិត្តភក្តិដែលអាក្រក់នោះទេ។ ដូច្នេះវីដេអូនេះពិតជាមានប្រយោជន៍ខ្លាំងណាស់" ។

*កញ្ញា ឈេង គន្ធា កម្មការិនីនៃសហគ្រាសតៃយៀន*

អង្គការពលកម្មអន្តរជាតិ
រោងចក្រកាន់តែប្រសើរនៅកម្ពុជា
ផ្ទះលេខ ៩ ផ្លូវលេខ ៣២២
បឹងកេងកង ១ ចំការមន
ភ្នំពេញ ប្រទេសកម្ពុជា

ប្រអប់សំបុត្រលេខ ២៦៨
ទូរស័ព្ទ: ៨៥៥.២៣ ២១២ ៨៤៧ / ២២០ ៣៦២
ទូរសារ: ៨៥៥.២៣ ២១២ ៩០៣
អ៊ីមេល: betterfactories@ilo.org
វិបសាយ: www.betterfactories.org/ilo

អង្គការ
ពលកម្ម
អន្តរជាតិ

**រោងចក្រ**
**កាន់តែប្រសើរ**
នៅកម្ពុជា

# សេចក្តីណែនាំអំពីការបណ្តុះបណ្តាលកម្មករនិយោជិតតាមរោងចក្រ



## "រៀនសូត្រទាំងអស់គ្នា"




## ទិដ្ឋភាពទូទៅ

ឧស្សាហកម្មកាត់ដេរដែលផ្តល់នូវការងារដល់កម្មករនិយោជិតចំនួនជិត ៣៥០,០០០នាក់ ជាវិស័យឧស្សាហកម្មការងារដែលធំជាងគេតែមួយគត់នៅកម្ពុជា ហើយជាវិស័យចម្បងដែលស្រូបយកចំណូលពីការនាំចេញឈានមុខគេសម្រាប់ប្រទេសនេះ។ ជាមួយនឹងកំណើននៃចំណាប់អារម្មណ៍ជាសកលលើល័ក្ខខ័ណ្ឌការងាររួមផ្សំនឹងបរិយាកាសប្រកួតប្រជែងដែលមានលក្ខណៈអន្តរជាតិ ធ្វើឱ្យមានតម្រូវការយ៉ាងខ្លាំងក្លាក្នុងការផ្តល់នូវការបណ្តុះបណ្តាលប្រកបដោយគុណភាពដើម្បីឆ្លើយតបតាមតម្រូវការភ្លាមៗរបស់អ្នកដែលពាក់ព័ន្ធសំខាន់ៗនៃឧស្សាហកម្មពោលគឺ កម្មករនិយោជិត ។ គំរោង *រោងចក្រកាន់តែប្រសើរនៅកម្ពុជា* នៃអង្គការពលកម្មអន្តរជាតិ បង្កើតនូវកម្មវិធីបណ្តុះបណ្តាលយ៉ាងសំបូរបែប ដើម្បីបំពេញសេចក្តីត្រូវការរបស់ឧស្សាហកម្មផលិតសំលៀកបំពាក់កម្ពុជា ។ ក្នុងកម្មវិធីបង្រៀនរបស់យើងមានការផ្តោតសំខាន់ទៅលើការធ្វើឱ្យប្រសើរឡើងនៃល័ក្ខខ័ណ្ឌការងារ ផលិតភាព និងគុណភាពតាមរយៈកិច្ចសហការនៅទីកន្លែងធ្វើការ។

ដោយផ្តោតសំខាន់លើកម្មករនិយោជិតតាមបណ្តារោងចក្រគំរោង *រោងចក្រកាន់តែប្រសើរនៅកម្ពុជា* បានបង្កើតនូវកម្មវិធីបណ្តុះបណ្តាល សម្រាប់ឧស្សាហកម្មផលិតសំលៀកបំពាក់នាំចេញកម្ពុជា ដោយប្រើប្រាស់ខ្សែវីដេអូ ជាវិធីបណ្តុះបណ្តាល។ វាជាកម្មវិធីបណ្តុះបណ្តាលដំបូងបង្អស់ក្នុងប្រទេសដែលផ្តោតលើការបង្កើនចំណេះដឹងដល់កម្មករនិយោជិតតាមរោងចក្រពីសិទ្ធិ និងទំនួលខុសត្រូវរបស់ពួកគេ។

ខ្សែវីដេអូពីរភាគដំបូង ទទួលបានការឧបត្ថម្ភពីមូលនិធិ GAP។ ខ្សែវីដេអូចាប់ពីភាគទី៣ រហូតដល់ភាគទី៦ ត្រូវបានឧបត្ថម្ភដោយមូលនិធិសហរដ្ឋអាមេរិច USAID។ ខ្សែវីដេអូពីរភាគទៀត កំពុងត្រូវបានផលិតក្រោមជំនួយថវិការពីក្រុមទីភ្នាក់ងារអភិវឌ្ឍន៍បារាំង AFD។

## រចនាសម្ព័ន្ធនៃការបណ្តុះបណ្តាល

ឯកសារបណ្តុះបណ្តាលកម្មករនិយោជិតតាមរោងចក្រទាំងអស់ មានរាប់បញ្ចូលទាំងខ្សែវីដេអូចំនួន៦ភាគរបស់រឿង "នៅមុខខ្លោងទ្វាររោងចក្រកាត់ដេរ" ភ្ជាប់ជាមួយនឹងសៀវភៅរូបថ្លុកដែលសង្ខេបអត្ថបទរឿងពីខ្សែវីដេអូ។ គ្រប់ឯកសាររបស់កម្មវិធីបណ្តុះបណ្តាលតាមរោងចក្រត្រូវបានរៀបចំឡើងសម្រាប់អ្នកមិនសូវចេះអក្សរដោយរាប់បញ្ចូលពីយេនឌ័រ ហើយសមស្របទៅនឹងក្រុមគោលដៅដែលភាគច្រើនជាកម្មករនិយោជិតស្ត្រីក្មេងៗ ។ ខ្សែវីដេអូទាំងនេះ មានការចូលរួមសម្តែងពីតារាភាពយន្តខ្មែរល្បីៗដោយរាប់បញ្ចូលទាំងវិនាដកម្ម អារម្មណ៍រំភើប និងភាពសប្បាយរីករាយ ដែលជាចរិកលក្ខណៈរបស់សាច់រឿងភាគនេះ។ ការរៀបចំនៃកម្មវិធីបណ្តុះបណ្តាល មានការទាក់ទងគ្នាយ៉ាងច្រើនជាមួយរោងចក្រដែលចូលរួម ។ ជាទូទៅនៅគ្រប់ទីកន្លែងទាំងអស់ មានកម្មករនិយោជិតប្រមាណពី ២០០ ទៅ ១០០០នាក់ ចូលរួមទស្សនាពេលមានការបញ្ចាំងម្តងៗ។

ពេលវេលា និងរយៈពេល: ដោយសារពេលវេលារបស់រោងចក្រមួយចំនួនធំមានកំណត់ ដូច្នេះដំណើរការទាំងមូល ត្រូវចំណាយពេលប្រហែលជា១ម៉ោង ហើយធ្វើឡើងកំឡុងពេលស្រស់ស្រូបអាហារថ្ងៃត្រង់។ ទោះជាយ៉ាងណាក៏ដោយ វគ្គបណ្តុះបណ្តាលទាំងនេះ គួរតែត្រូវបានធ្វើឡើងក្នុងម៉ោងធ្វើការដើម្បីឱ្យមានអត្រាចូលរួមកាន់តែខ្ពស់ និងពេលវេលាបន្ថែមសម្រាប់សំណួរ និងចម្លើយដែលអាចបង្កើតឱ្យមានការយល់ដឹងកាន់តែប្រសើរលើសារសំខាន់ៗ។ ចំពោះពីរភាគដំបូង វាជាធម្មតាត្រូវបានធ្វើឡើងក្នុងរយៈពេល២ថ្ងៃជាប់ៗគ្នា ដោយសារតែភាគទី២ជាភាគបន្តពីភាគទី១។ ភាគនីមួយៗ មានរយៈពេលពី ២៥ទៅ៣០នាទី។

ទីកន្លែង: ទីកន្លែងនឹងមានការប្រែប្រួលទៅតាមរោងចក្រ។ ទីកន្លែងដែលអាចធ្វើទៅបានរួមមានកន្លែងអាហារដ្ឋាន ឬកន្លែងផ្សេងទៀតរបស់រោងចក្រ ។

## វិធីសាស្រ្ត

វិធីសាស្រ្តនៃការបណ្តុះបណ្តាល ធ្វើតាមបែបផ្តល់ព័ត៌មាន និងបែបចូលរួម។ គ្រូបណ្តុះបណ្តាលរបស់ គំរោង *រោងចក្រកាន់តែប្រសើរនៅកម្ពុជា* ចាប់ផ្តើមដោយបង្កើតឈុតសម្រាប់រឿងនីមួយៗ ហើយសាកសួរគំនិតរបស់កម្មករនិយោជិតអំពីអ្វីដែលអាចកើតមានឡើង។ នៅពេលបញ្ចាំងខ្សែវីដេអូ អ្នកចូលរួមអាចផ្សារភ្ជាប់បទពិសោធន៍ការងារជាក់ស្តែងរបស់ពួកគេទៅកាន់បញ្ហាទាំងឡាយនៅក្នុងខ្សែវីដេអូ ហើយមានឱកាសក្នុងការចែករំលែកទស្សនៈ និងមតិយោបល់របស់ពួកគេដោយការឆ្លើយទៅនឹងសំនួរដែលសួរក្រោយពេលទស្សនារួច។ បន្ទាប់មកគ្រូបណ្តុះបណ្តាលធានាបានថាកម្មករនិយោជិតបានយល់ពីសារសំខាន់ៗសម្រាប់ប្រធានបទនីមួយៗ។ សៀវភៅរូបថ្លុក នឹងត្រូវចែកជូនទៅដល់អ្នកចូលរួមទាំងអស់ទុកជាឯកសារ ដើម្បីអោយពួកគេអាចបន្តស្វែងយល់កាន់តែស៊ីជំរៅអំពីបញ្ហាទាំងនេះដោយខ្លួនឯងបាន ហើយសង្ឃឹមថាពួកគេអាចចែករំលែកសៀវភៅរូបថ្លុកនេះជាមួយអ្នកដទៃទៀតដែលមិនបានទស្សនាវីដេអូ។ គោលបំណងសំខាន់ គឺចង់ផ្តល់អោយអ្នកចូលរួមនូវបទពិសោធន៍នៃការសិក្សាមួយដែលមានលក្ខណៈសប្បាយរីករាយ និងបន្ទូរបន្ថយបរិយាកាសតានតឹងដែលមានសារជាគន្លឹះសំខាន់ៗ ពាក់ព័ន្ធទៅនឹងសិទ្ធិ និងការទទួលខុសត្រូវរបស់កម្មករនិយោជិត។



ខ្សែវីដេអូ សៀវភៅរូបថ្លុក និងការសំរបសំរួលការបណ្តុះបណ្តាលត្រូវបានផ្តល់ជូនជាភាសាខ្មែរ។

## មាតិការ

មាតិការរបស់ខ្សែវីដេអូទាំងនេះ រួមមាន:

១. ការដោះស្រាយការកើតទុក្ខមិនសុខចិត្ត

២.ការដោះស្រាយវិវាទ (ផ្តល់ឱកាសអោយអ្នកគ្រប់គ្រងដោះស្រាយបញ្ហាជាមុនសិន ) និងកូដកម្មស្របច្បាប់

៣. ការលួច

៤. សុវត្ថិភាព និងសុខភាពការងារ -ប្រើប្រាស់វិធីសាស្រ្តការពារ

៥. ម្តាយជាអ្នកធ្វើការ និងការបំបៅដោះកូន (លើកកំពស់អោយមានការបំបៅដោះកូនតែមួយមុខគត់)

៦. កម្មករនិយោជិត មិនទាន់គ្រប់អាយុ / មិនចំណាយលុយដើម្បីបានការងារធ្វើ

## ហេតុអ្វីការបណ្តុះបណ្តាលនេះមានសារៈសំខាន់?

- បង្កើនឱ្យមានការយល់ដឹងពីការសហការគ្នានៅកន្លែងធ្វើការ
- ធ្វើឱ្យប្រសើរឡើងនូវទំនាក់ទំនងវិជ្ជាជីវៈ ផលិតភាព និងគុណភាព
- ធ្វើឱ្យសំរេចបាននូវនិរន្តរភាពនៃការផ្លាស់ប្តូរ
- ដើម្បីការពារកូដកម្ម ជម្លោះ ឬឧបសគ្គផ្សេងទៀតចំពោះ ផលិតភាពរោងចក្រ និងទំនាក់ទំនងវិជ្ជាជីវៈ
- ដើម្បីធ្វើតាមកំណើននៃតម្រូវការជាសកលស្តីពីទំនាក់ទំនងវិជ្ជាជីវៈ ឬកផ្សំនឹងបរិយាកាសប្រកួតប្រជែងជាលក្ខណៈអន្តរជាតិ
- ជាការផ្តល់ឱកាសឱ្យអ្នកចូលរួមទាំងអស់នូវពេលវេលាស្វែងយល់ពីបញ្ហាជាកង្វល់ផ្សេងៗ និងមធ្យោបាយជាក់ស្តែងសម្រាប់អ្នកគ្រប់គ្នា
- បង្កើតជាឱកាសដើម្បីរៀនសូត្រទាំងអស់គ្នា និងរៀនពីគ្នាទៅវិញទៅមកដោយបង្កើតជាការប្រមូលផ្តុំនូវចំណេះវិជ្ជា។ ការចែករំលែកគំនិតនឹងផ្តល់លទ្ធផលជាវិជ្ជមានមកលើកិច្ចសហការគ្នាក្នុងកន្លែងធ្វើការតាមរយៈធ្វើឱ្យប្រសើរឡើងនូវទំនាក់ទំនង និងការយោគយល់អធ្យាស្រ័យគ្នា។

## អ្នកផ្តល់ការបណ្តុះបណ្តាល

កម្មវិធីនេះ អនុវត្តដោយក្រុមការងារផ្នែកបណ្តុះបណ្តាលរបស់គំរោង *រោងចក្រកាន់តែប្រសើរនៅកម្ពុជា* ដែលជាអ្នកមានបទពិសោធន៍ទាក់ទងទៅនឹងការផ្តល់ការបណ្តុះបណ្តាលជំនាញដល់ឧស្សាហកម្មកាត់ដេរ ។



## ព័ត៌មានលំអិត

គ្រប់ភាគីទាំងអស់ ដែលមានចំណាប់អារម្មណ៍ ហើយត្រូវការព័ត៌មានបន្ថែមអំពីគំនិតផ្តួចផ្តើមនេះ ឬចង់ធានាថារោងចក្ររបស់ពួកគេពិតជាទទួលបានការបណ្តុះបណ្តាលកម្មករនិយោជិត តាមរោងចក្រនេះសូមទាក់ទងមក *លោក នៅ តារា* តាមរយៈអ៊ីមែល dara@ilo.org ឬ ទូរស័ព្ទលេខ (៨៥៥-២៣)២១២ ៨៤៧ លេខបន្ត ១១៩ ឬ *កញ្ញា លាង ចន្ធី* តាមរយៈអ៊ីមែល chanthy@ilo.org ឬ ទូរស័ព្ទលេខ (៨៥៥-២៣) ២១២ ៨៤៧ លេខបន្ត ២២៩។